| ២៦-លោក | **ហាយ ស៊ុន** | មន្ត្រី អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ |
| ២៧-លោកស្រី | **ចាន់ លាត** | មន្ត្រី អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ |
| ២៨-លោកស្រី | **ចាង្ស ចំនួម៉ូលី** | អនុប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋបាល |
| ២៩-លោក | **ម៉ែង គីមស៊េង** | ប្រធានការិយាល័យ នៃនាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច |
| ៣០-លោក | **ឈឹម ចាន់ដន** | អនុប្រធានការិយាល័យ នៃនាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច |
| ៣១-លោកស្រី | **សេង សុមេត្តា** | មន្ត្រី នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច |
| ៣២-លោក | **គីម អ៊ុត** | អនុប្រធានការិយាល័យ នៃនាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច |
| ៣៣-លោក | **ឈៀង ថាវរិទ្ធ** | អនុប្រធានការិយាល័យនៃនាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច |
| ៣៤-លោក | **ខួន បុណ្ណមី** | មន្ត្រី នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច |
| ៣៥-លោក | **ស៊ូម៉ៃ សុខគា** | មន្ត្រី នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច |
| ៣៦-លោក | **ស៊ិន ម៉េងហុង** | មន្ត្រី នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច |
| ៣៧-លោក | **ជា ប្រុសណិត** | មន្ត្រី នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច |
| ៣៨-លោកស្រី | **ខែត សុថា** | មន្ត្រី នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច |
| ៣៩-លោក | **សុខ ដារ៉ាវុធ** | អនុប្រធានការិយាល័យ នៃនាយកដ្ឋានបុគ្គលិក |
| ៤០-លោក | **គាំង ទ៉ាន់ថា** | មន្ត្រី នាយកដ្ឋានឧស្សាហកម្ម និងសំណង់ |
| ៤១-លោកស្រី | **គីម សុគន្ធា** | មន្ត្រី នាយកដ្ឋានពិធីការ |
| ៤២-លោកស្រី | **ស៊ឹម នី** | មន្ត្រី នាយកដ្ឋានពិធីការ |
| ៤៣-លោកស្រី | **កែ សំណាង** | មន្ត្រី នាយកដ្ឋានពិធីការ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។៚

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ ០៣ ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ [illegible] អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជាតិ គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណៈការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណៈការ និងដឹកជញ្ជូន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើតគណៈកម្មាធិការជាតិ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រ អនុសាសន៍ គោលនយោបាយ និងវិធានការ ពាក់ព័ន្ធទាំងឡាយ របស់គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ ។

**មាត្រា ២.-**

គណៈកម្មាធិការជាតិ គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ មានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| - ឯកឧត្តម **សុខ អាន** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| - ឯកឧត្តម **គាត ឈន់** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| - ឯកឧត្តម **ស៊ុន ចាន់ថុល** | រដ្ឋមន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន | អនុប្រធានប្រចាំការ |
| - ឯកឧត្តម **កៅ គីមហួន** | រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធានអចិន្ត្រៃយ៍ |
| - ឯកឧត្តម **ចម ប្រសិទ្ធ** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីទទួលបន្ទុកការងារ AMBDC | សមាជិក |
| - អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | | សមាជិក |
| - អនុរដ្ឋលេខាធិការ ក្រសួងផែនការ | | សមាជិក |
| - អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | | សមាជិក |
| - អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន | | សមាជិក |
| - អនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | សមាជិក |
| - អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | សមាជិក |
| - អនុរដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | | សមាជិក |
| - អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ | | សមាជិក |
| - អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | | សមាជិក |
| - តំណាង គណៈកម្មាធិការព្រំដែន | | សមាជិក |
| - អគ្គលេខាធិការរង អាជ្ញាធរកំចាត់មីនកម្ពុជា | | សមាជិក |
| - អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ | | សមាជិក |
| - ប្រធានអគ្គនាយក រាជាយស្ម័យយានកម្ពុជា | | សមាជិកអចិន្ត្រៃយ៍ |

**មាត្រា ៣.-**

គណៈកម្មាធិការជាតិ គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ មានក្រុមការងារបច្ចេកទេសមួយជាជំនួយការ ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| - ប្រធានអគ្គនាយក រាជាយស្ម័យយានកម្ពុជា | ប្រធាន |
| - តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| - ប្រធាននាយកដ្ឋាន គមនាគមន៍ និងប្រៃសណីយ៍ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - ប្រធាននាយកដ្ឋានអាស៊ាន ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

- ប្រធាននាយកដ្ឋាន ផែនការ-ស្ថិតិ ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
- ប្រធាននាយកដ្ឋាន ទំនាក់ទំនងអន្តរជាតិ ក្រសួងផែនការ សមាជិក
- តំណាង ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ សមាជិក
- តំណាង ក្រសួងបរិស្ថាន សមាជិក
- តំណាង ក្រសួងការពារជាតិ សមាជិក
- តំណាង ក្រសួងមហាផ្ទៃ សមាជិក
- នាយក ផ្លូវ ស្ពាន អាគារ រាជាយស្វ័យយានកម្ពុជា សមាជិក
- អភិបាលស្រុកពាក់ព័ន្ធ សមាជិក
- នាយករងរដ្ឋបាលទទួលបន្ទុកការិយាល័យផែនការ-ស្ថិតិ រអយក លេខាធិការអចិន្ត្រៃយ៍

## ជំពូកទី ៣
## តួនាទី និង ភារកិច្ច

**មាត្រា ៤.-**

គណៈកម្មាធិការជាតិ មានភារកិច្ច :

- ដឹកនាំ គ្រប់គ្រង សំរបសំរួលការងារលើគ្រប់សកម្មភាពក្នុងគំរោងផ្លូវដែកសិង្ហបុរី-គុនមីញ
- លើកសំណើជូន រាជរដ្ឋាភិបាល ពិនិត្យ និងសំរេច លើសកម្មភាពអនុវត្តគំរោងស្តារ និងកសាងផ្លូវដែកកម្ពុជា មានជាអាទិ៍ :
  - ដោះស្រាយហិរញ្ញប្បទានទាំងក្នុងប្រទេស និងក្រៅប្រទេស
  - ដោះស្រាយផលប៉ះពាល់ដីធ្លី ផ្ទះសំបែងរបស់ប្រជាពលរដ្ឋ ក្នុងគំរោងសាងសង់
  - ការដោះមីន និងអាវុធយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ តាមបណ្តោយផ្លូវដែកដែលត្រូវស្តារ និងសាងសង់
  - លើកគំរោងប៉ាន់ស្មានតំលៃអនុវត្តកំណាត់ផ្លូវដែកនីមួយៗក្នុងទឹកដីកម្ពុជា
- ចូលរួមប្រជុំពិភាក្សាការងារជាមួយបណ្តាប្រទេសអាស៊ាន និងដៃគូអភិវឌ្ឍន៍នានា លើការងារអនុវត្តន៍គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពនានា និងលទ្ធផលការងារក្នុងការអនុវត្តន៍គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ ជូនប្រមុខរាជរដ្ឋាភិបាល។

**មាត្រា ៥.-**

ក្រុមការងារបច្ចេកទេសមានភារកិច្ច :

- សិក្សាស្រាវជ្រាវបច្ចេកវិទ្យាដែលមានសារៈប្រយោជន៍ ដល់ការងារអនុវត្តន៍គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ
- រៀបចំរាល់ឯកសារបច្ចេកទេសពាក់ព័ន្ធនឹងគំរោងដាក់ជូនគណៈកម្មាធិការជាតិ ដើម្បីពិនិត្យ និងសំរេច

- ចូលរួមការងារ និងសិក្សាស្រាវជ្រាវជាមួយក្រុមការងារបច្ចេកទេសនៃបណ្តាប្រទេសអាស៊ានទៅតាមតួនាទី និងភារកិច្ចរបស់ខ្លួន
- ចូលរួមផ្តល់យោបល់រាល់កិច្ចប្រជុំតាមការអញ្ជើញរបស់គណៈកម្មាធិការជាតិ
- ប្រមូលទិន្នន័យការងារ និងឯកសារបច្ចេកទេសនានា យកមកចងក្រងធ្វើរបាយការណ៍ជូនគណៈកម្មាធិការជាតិ និងទុកជាឯកសារសំរាប់តាមដានការអនុវត្តន៍គំរោង
- ទទួលការងារផ្សេងទៀតដែលគណៈកម្មាធិការជាតិប្រគល់អោយ ។

## ជំពូកទី ៤

## ថវិកាសំរាប់អនុវត្តន៍គំរោង

**មាត្រា ៦.-**

គណៈកម្មាធិការជាតិ គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ មានកញ្ចប់ថវិកាដោយឡែក ។

## ជំពូកទី ៥

## អន្តរប្បញ្ញត្តិ

**មាត្រា ៧.-**

គណៈកម្មាធិការជាតិ គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ត្រាជាផ្លូវការរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការទំនាក់ទំនងការងាររបស់ខ្លួន ។

ប្រធានគណៈកម្មាធិការជាតិ អាចអញ្ជើញតំណាងពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ ឬ អ្នកបច្ចេកទេសដទៃទៀត មកចូលរួមប្រជុំតាមការចាំបាច់ ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ៨.-**

អនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិ គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ អនុក្រឹត្យលេខ១៤៩ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលមាត្រា ២ និង មាត្រា ៣ នៃអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិ គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ គណៈកម្មាធិការចំរុះកិច្ចការព្រំដែន អាជ្ញាធរកំចាត់មីនកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃគ្រប់ក្រសួង-ស្ថាប័ន និងអភិបាលខេត្ត-ក្រុង ពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា ៩*
*-ឯកសារ- កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៧.៣.៣...អនក្រ.បក-៩៩

## អនុក្រឹត្យ

## ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១:** ត្រូវបានប្រគល់ភារកិច្ចជូនលោក **ឡាយ ម៉ូរិន** ឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋានសំភារៈ និងទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងអប់រំ យុវជន និងកីឡា ជំនួសលោក **ឡោ ឡាត់** ដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍ ។

**មាត្រា ២:** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ...[illegible] - បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សមាជិកជ្រើសតាំង និងសមាសភាពការិយាល័យប្រតិបត្តិ សំរាប់សភាពាណិជ្ជកម្មខេត្តពោធិសាត់ អាណត្តិទី១ លើកទី១

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម
- បាន[illegible]អនុក្រឹត្យលេខ ៥៦ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការបង្កើតសភាពាណិជ្ជកម្ម ខេត្ត[illegible]ធិសាត
- បានឃើញកំណត់ហេតុ ស្តី[illegible]ទ្ធផលនៃការបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំង នៃសភាពាណិជ្ជកម្មខេត្តពោធិសាត់ អាណត្តិទី១ កាលពីថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៦
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

**មាត្រា ១.-**

ទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្មខេត្តពោធិសាត់ ចំនួន ១៥ រូប ដូចខាងក្រោម :

១- លោក **កែវ រិទ្ធី**
២- លោក **នុយ គី**
៣- លោក **តូច ឃាវ**
៤- លោក **ខាត់ ថៃ**
៥- លោក **អ៊ុំ ជីតិច**
៦- លោក **ផែន សុគន្ធ**
៧- លោក **អ៊ុក បូរ៉ាត់**
៨- លោក **ជា គា**
៩- លោក **ខូយ ទេត**
១០- លោក **ឡាយ សូយ**
១១- លោក **តែ សុខធី**
១២- លោក **ឡេង ហួត**
១៣- លោក **ហៀង សុផល**
១៤- លោក **នូ គីមស៊ាន**
១៥- លោក **ឡេង សារុន**

**មាត្រា ២.-**

ទទួលស្គាល់លោក **នុយ គី** ជាប្រធានសភាពាណិជ្ជកម្មខេត្តពោធិសាត់ ។

**មាត្រា ៣.-**

ទទួលស្គាល់ការបង្កើតការិយាល័យប្រតិបត្តិមួយរបស់សភាពាណិជ្ជកម្មខេត្តពោធិសាត់ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- លោក | **នុយ គី** | ជាប្រធាន |
| ២- លោក | **កែវ រិទ្ធី** | ជាអនុប្រធាន |
| ៣- លោក | **ផែន សុគន្ធ** | ជាអនុប្រធាន |
| ៤- លោក | **នូ គីមស៊ាន** | ជាអនុប្រធាន |
| ៥- លោក | **ឡេង សារុន** | ជាអនុប្រធាន |
| ៦- លោក | **ឡេង ហួត** | ជាអនុប្រធាន |
| ៧- លោក | **តែ សុខធី** | ជាហិរញ្ញិក |
| ៨- លោក | **ខាត់ ថៃ** | ជាលេខាធិការ |

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តពោធិសាត់ ប្រធានសភាពាណិជ្ជកម្មខេត្តពោធិសាត់ និងសាមីខ្លួន ដែលមានចែងក្នុងមាត្រា១ មាត្រា២ និងមាត្រា៣ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ដូចមាត្រា៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ២៣៥ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការទទួលស្គាល់សមាជិកជ្រើសតាំង និងសមាសភាពការិយាល័យប្រតិបត្តិ សំរាប់សភាពាណិជ្ជកម្មខេត្តកំពង់ស្ពឺ អាណត្តិទី១ លើកទី១

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទិ ២២ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទិ ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្ដីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទិ ១៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្ដីពីការបង្កើតសភាពាណិជ្ជកម្ម ខេត្តកំពង់ស្ពឺ
- បានឃើញកំណត់ហេតុ ស្ដីពីលទ្ធផលនៃការបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំង នៃសភាពាណិជ្ជកម្មខេត្តកំពង់ស្ពឺ អាណត្តិទី១ កាលពីថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៦
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

**មាត្រា ១.-**

ទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្មខេត្តកំពង់ស្ពឺ ចំនួន ១៥ រូប ដែលបែងចែកតាម ប្រភេទអាជីវកម្ម ដូចខាងក្រោម :

**ប្រភេទពាណិជ្ជកម្ម**

១- លោក **ណាំ ស្រ៊ុន**
២- លោក **អ៊ុំ ឈុនធ្វី**
៣- លោក **តាន់ ស៊ីមន**
៤- លោក **អ៊ូ ទ៉ែត**

**ប្រភេទឧស្សាហកម្ម សិប្បកម្ម**

១- លោក **ជៀម ភាក់**
២- លោក **ឡុង ហេង**
៣- លោក **អ៊ុន យុន្នី**
៤- លោក **ជា គុកខុង**

**ប្រភេទសេវាកម្ម និងទិជ្ជាជីវៈ**

១- លោក **សៀង ឌុច**
២- លោក **សាន់ ម៉ៅ**
៣- លោក **ឡេង ម៉ុច**
៤- លោក **ឡេង លី**

**ប្រភេទកសិកម្ម**

១- លោក **ចាន់ សុជាតិ**
២- លោក **ទូ សេង**
៣- លោកស្រី **គាំង ផល្លា**

**មាត្រា ២.-**

ទទួលស្គាល់លោក **ណាំ ស្រ៊ុន** ជាប្រធានសភាពាណិជ្ជកម្មខេត្តកំពង់ស្ពឺ ។

**មាត្រា ៣.-**

ទទួលស្គាល់ការបង្កើតការិយាល័យប្រតិបត្តិមួយរបស់សភាពាណិជ្ជកម្មខេត្តកំពង់ស្ពឺ ដែលមាន សមាសភាពដូចខាងក្រោម :

១- លោក **ណាំ ស្រ៊ុន** ជាប្រធាន
២- លោក **អ៊ុំ ឈុនធ្វី** ជាអនុប្រធាន
៣- លោក **សៀង ឌុច** ជាអនុប្រធាន
៤- លោក **ជៀម ភាក់** ជាអនុប្រធាន
៥- លោក **ចាន់ សុជាតិ** ជាអនុប្រធាន

៦- លោក **សាន់ ម៉ៅ** ជាហិរញ្ញិក

៧- លោកស្រី **ភាំង ផល្លា** ជាហិរញ្ញិករងទី១

៨- លោក **អ៊ូ ទ៉ែត** ជាហិរញ្ញិករងទី២

៩- លោក **ឡេង ម៉ូវ** ជាលេខាធិការ

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តកំពង់ស្ពឺ ប្រធានសភាពាណិជ្ជកម្មខេត្តកំពង់ស្ពឺ និងសាមីខ្លួន ដែលមានចែងក្នុងមាត្រា១ មាត្រា២ និងមាត្រា៣ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងសមាសភាពតំណាងប្រមុខរាជរដ្ឋាភិបាល ក្នុងក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ / ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែល ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- យោងតាមសំណើរបស់ទេសាភិបាលធនាគារជាតិនៃកម្ពុជា

## សំរេច

**មាត្រា ១ :** ត្រូវបានតែងតាំងឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** ជា **សមាជិកក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា** តំណាងអោយប្រមុខរាជរដ្ឋាភិបាល ជាថ្មីម្តងទៀត បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ២៣.០៣.០៧...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

**សម្រេច**

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនឧកញ៉ា **លឹម សួសារិទ្ធ** ដែលមានស្នាដៃល្អ និងគុណ បំណាច់ខ្ពស់ ក្នុងការរួមចំណែកជួយកសាង និងអភិវឌ្ឍន៍ វិស័យអប់រំ និងសង្គមកិច្ច នៅខេត្តតាកែវ ។

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធ ផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ មិនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ២៣៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚៚

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន៣៥រូប ដែលបានបរិច្ចាគធនធានជួយកសាងសមិទ្ធផលនានា នៅវត្ត ភ្នីមាស ឃុំព្រៃផ្តៅ ស្រុកព្រៃកប្បាស ខេត្តតាកែវ ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

**ក.មេដាយមាសស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-លោកជំទាវ | **ស៊ុន អេង** | នៅក្រុងភ្នំពេញ | ថវិកាចំនួន | ១២.៥០០ ដុល្លារ |
| ២-អង្គការ | **អាភគី** (ARK) | ប្រទេសជប៉ុន | ថវិកា ចំនួន | ១៧.៤៣៧ ដុល្លារ |
| ៣-ឧបាសក | **ភាំង ណាំហេង** | នៅក្រុងភ្នំពេញ | ថវិកាចំនួន | ១១.៤១៥ ដុល្លារ |
| ៤-ឧបាសិកា | **ធីង អូន** | នៅសហរដ្ឋអាមេរិក | ថវិកាចំនួន | ១១.៣១០ ដុល្លារ |
| ៥-លោក | **សេន តៃ** | នៅសហរដ្ឋអាមេរិក | ថវិកាចំនួន | ១១.២២០ ដុល្លារ |
| ៦-ព្រះតេជគុណ | **សុភ ឆិល** | ចៅអធិការវត្ត ភ្នីមាស | ថវិកាចំនួន | ១០.១៩០ ដុល្លារ |
| ៧-លោក | **មុត តូ** | នៅឃុំតាំងយ៉ាប ព្រៃកប្បាស តាកែវ | ថវិកាចំនួន | ១០.០២០ ដុល្លារ |
| ៨-ឧបាសិកា | **សេន ច្រាយ** | នៅសហរដ្ឋអាមេរិក | ថវិកាចំនួន | ១០.០១៨ ដុល្លារ |
| ៩-លោក | **យុន ម៉ិនឡេង** | នៅក្រុងភ្នំពេញ | ថវិកាចំនួន | ១០.០១៥ ដុល្លារ |
| ១០-ឧបាសក | **ចូ៉ម អ៊ាវចន** | នៅឃុំព្រៃល្វា ព្រៃកប្បាស តាកែវ | ថវិកាចំនួន | ១០.០០០ ដុល្លារ |
| ១១-លោកតា | **ឈឹម ភួង** | នៅក្រុងភ្នំពេញ | ថវិកាចំនួន | ១០.០០០ ដុល្លារ |
| ១២-លោកយាយ | **អ៊ឹង ឈួង** | នៅក្រុងភ្នំពេញ | ថវិកាចំនួន | ១០.០០០ ដុល្លារ |
| ១៣-លោក | **ឈឹម គីមឆុង** | នៅប្រទេសសឹង្ហបុរី | ថវិកាចំនួន | ១០.០០០ ដុល្លារ |

**ខ. មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | | | | |
|---|---|---|---|---|---|---|
| ១-លោក | ហ៊ិត | លាងគីម | នៅក្រុងភ្នំពេញ | ថវិកាចំនួន | ៧.៣៣៥ | ដុល្លារ |
| ២-លោក | ហោ | ម៉ិនឆាង | នៅសហរដ្ឋអាមេរិក | ថវិកាចំនួន | ៧.១២០ | ដុល្លារ |
| ៣-លោក | ជ័យ | សំណាង | នៅសហរដ្ឋអាមេរិក | ថវិកាចំនួន | ៦.៣១៥ | ដុល្លារ |
| ៤-ឧបាសក | ង៉ែត | តាំងនី | នៅក្រុងភ្នំពេញ | ថវិកាចំនួន | ៦.៣១០ | ដុល្លារ |
| ៥-លោក | ម៉ៅ | សាម៉ន | នៅឃុំតាំងយ៉ាប ព្រៃកប្បាស តាកែវ | ថវិកាចំនួន | ៥.៦១២ | ដុល្លារ |
| ៦-លោក | ឡាក់ | គីមសាង | នៅឃុំព្រៃផ្ដៅ ព្រៃកប្បាស តាកែវ | ថវិកាចំនួន | ៥.៥៤២ | ដុល្លារ |
| ៧-ឧបាសិកា | គុយ | គីមហ៊ី | នៅសហរដ្ឋអាមេរិក | ថវិកាចំនួន | ៥.៤១៥ | ដុល្លារ |
| ៨-លោក | ង៉ែ | ស្រ៊ុម | នៅឃុំព្រៃផ្ដៅ ព្រៃកប្បាស តាកែវ | ថវិកាចំនួន | ៥.២០៥ | ដុល្លារ |
| ៩-លោក | ឆុច | សយ | នៅឃុំតាំងយ៉ាប ព្រៃកប្បាស តាកែវ | ថវិកាចំនួន | ៥.១៧៣ | ដុល្លារ |
| ១០-លោកអាចារ្យ | ឡុង | ញ៉ឹត | នៅឃុំព្រៃផ្ដៅ ព្រៃកប្បាស តាកែវ | ថវិកាចំនួន | ៥.១៥០ | ដុល្លារ |

**គ. មេដាយសំរឹទ្ធស្ថាបនាជាតិ :**

| | | | | | | |
|---|---|---|---|---|---|---|
| ១-ឧបាសិកា | ហ៊ិត | ឡូច | យាយជីនៅវត្តភ្ជីមាស | ថវិកាចំនួន | ៣.៤១៥ | ដុល្លារ |
| ២-លោក | ឆុយ | អឿន | នៅឃុំព្រៃផ្ដៅ ព្រៃកប្បាស តាកែវ | ថវិកាចំនួន | ៣.២១០ | ដុល្លារ |
| ៣-ឧបាសក | សេង | ប៊ូ | នៅឃុំព្រៃផ្ដៅ ព្រៃកប្បាស តាកែវ | ថវិកាចំនួន | ២.០១២ | ដុល្លារ |
| ៤-លោក | ព្រាំ | ស៊ុម | នៅឃុំចំប៉ា ព្រៃកប្បាស តាកែវ | ថវិកាចំនួន | ១.៤៣២ | ដុល្លារ |
| ៥-លោក | ចែ | មាន | នៅឃុំព្រៃផ្ដៅ ព្រៃកប្បាស តាកែវ | ថវិកាចំនួន | ១.៣១៤ | ដុល្លារ |
| ៦-លោក | កែ | ឡាយ | នៅឃុំព្រៃផ្ដៅ ព្រៃកប្បាស តាកែវ | ថវិកាចំនួន | ១.២១៥ | ដុល្លារ |
| ៧-លោក | សុខ | អឿ | នៅឃុំព្រៃផ្ដៅ ព្រៃកប្បាស តាកែវ | ថវិកាចំនួន | ១.២១០ | ដុល្លារ |
| ៨-លោក | នា | សុខា | នៅឃុំព្រៃផ្ដៅ ព្រៃកប្បាស តាកែវ | ថវិកាចំនួន | ១.១១៥ | ដុល្លារ |
| ៩-លោក | ឆិត | ហ៊ើល | នៅឃុំព្រៃផ្ដៅ ព្រៃកប្បាស តាកែវ | ថវិកាចំនួន | ១.១១០ | ដុល្លារ |
| ១០-លោក | អ៊ុង | អាង | នៅឃុំព្រៃផ្ដៅ ព្រៃកប្បាស តាកែវ | ថវិកាចំនួន | ១.០៦០ | ដុល្លារ |
| ១១-លោក | ភង | អ៊ែត | នៅឃុំព្រៃផ្ដៅ ព្រៃកប្បាស តាកែវ | ថវិកាចំនួន | ១.០៥០ | ដុល្លារ |
| ១២-លោក | ស៊ុយ | សាវឿន | នៅឃុំព្រៃផ្ដៅ ព្រៃកប្បាស តាកែវ | ថវិកាចំនួន | ១.០៣០ | ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:.....២៣៩.....អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៣៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តកណ្តាល

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ជូនលោក **SAKAMOTO SUNAO** សប្បុរសជនជប៉ុន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលផ្សេងៗ ក្នុងវិស័យ អប់រំ សង្គមកិច្ច និងជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋកម្ពុជា ចំណាយអស់ទឹកប្រាក់ ចំនួន ១២៤.៥០០ ដុល្លារអាមេរិក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ២៤០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តកណ្តាល

### សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនជប៉ុន ចំនួន ០២រូប ដែលបានបរិច្ចាគថវិកាជួយកសាងវិស័យអប់រំ សង្គមកិច្ច នៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :-

១-លោក KURIHARA HIROSHI ទឹកប្រាក់ ចំនួន ១៩.០០០ ដុល្លារ

២-លោក KURIHARA TOMIKO ទឹកប្រាក់ ចំនួន ១១.០០០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ...១១...សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការរៀបចំសិក្ខាសាលា
## អន្តរក្រសួង មហាផ្ទៃ និងសាធារណការ និងដឹកជញ្ជូន
## ស្តីពីការគ្រប់គ្រងសណ្តាប់ធ្នាប់ សុវត្ថិភាពចរាចរណ៍ផ្លូវគោក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញក្រឹត្យលេខ ៦៨ ក្រ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- ពិនិត្យឃើញស្ថានភាពគ្រោះថ្នាក់ចរាចរនាពេលបច្ចុប្បន្នមានការកើនឡើង បណ្តាលឱ្យប៉ះពាល់ដល់អាយុជីវិត និងទ្រព្យសម្បត្តិប្រជាពលរដ្ឋ និងទ្រព្យសម្បត្តិសាធារណៈ

## សម្រេច

**ប្រការ១ :** បង្កើតគណៈកម្មការដើម្បីរៀបចំសិក្ខាសាលាអន្តរក្រសួង មហាផ្ទៃ និងសាធារណការ និងដឹកជញ្ជូន ស្តីពីការគ្រប់គ្រងសណ្តាប់ធ្នាប់ សុវត្ថិភាពចរាចរណ៍ផ្លូវគោក ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម **ឯម សំអាន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២- ឯកឧត្តម **ជុំ អៀក** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ជាអនុប្រធាន |
| ៣- ឯកឧត្តម ឧត្តមសេនីយ៍ឯក **សូរ ផន** | អគ្គស្នងការរងទី ១ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | ជាសមាជិក |
| ៤- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ស៊ឹម សុផល** | អគ្គស្នងការរងនគរបាលជាតិ | ជាសមាជិកអចិន្ត្រៃយ៍ |
| ៥- ឯកឧត្តម **ឡេង ធនយុទ្ធា** | អគ្គនាយក នៃអគ្គនាយកដ្ឋានដឹកជញ្ជូន ក្រសួងសាធារណការ និងដឹកជញ្ជូន | ជាសមាជិក |
| ៦- លោក ឧត្តមសេនីយ៍ទោ **ណុប ស៊ីណូ** | ប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ ក្រសួងមហាផ្ទៃ | ជាសមាជិក |

| | | |
|---|---|---|
| ៧- លោក ឧត្តមសេនីយ៍ត្រី **ចំនួ ឫទ្ធិ** | ប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់ ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៨- លោក **អ៊ុំ ជុនហួរ** | ប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ក្រសួងសាធារណការ និងដឹកជញ្ជូន | ជាសមាជិក |
| ៩- លោក វរសេនីយ៍ឯក **ផូ ខន** | អនុប្រធានទី ១ នាយកដ្ឋានសណ្តាប់ធ្នាប់ ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១០- លោក វរសេនីយ៍ឯក **ហ៊ឹម យ៉ាន** | អនុប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១១- លោក **ស្រី សិរីវឌ្ឍន៍** | អនុប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ក្រសួងសាធារណការ និងដឹកជញ្ជូន | ជាសមាជិក |
| ១២- លោក **កែវ សាវិន** | អនុប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ក្រសួងសាធារណការ និងដឹកជញ្ជូន | ជាសមាជិក |

**ប្រការ២ :** ភារកិច្ចរបស់គណៈកម្មការនេះរួមមាន :

- រៀបចំទីកន្លែងប្រារព្ធពិធី កំណត់ពេលវេលា និងកម្មវិធីសិក្ខាសាលា
- រៀបចំខ្លឹមសារឯកសារនានា ដែលពាក់ព័ន្ធនឹងសិក្ខាសាលា
- រៀបចំពិធីការ បដិសណ្ឋារកិច្ច និងអញ្ជើញភ្ញៀវជាតិ និងអន្តរជាតិចូលរួមសិក្ខាសាលា
- រៀបចំសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់
- ធ្វើគំរោងចំណាយផ្សេងៗសម្រាប់បម្រើឱ្យកិច្ចដំណើរការសិក្ខាសាលា និងដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសម្រេច ។

**ប្រការ៣ :** - គណៈកម្មការនេះមានសិទ្ធិបង្កើតអនុគណៈកម្មការ ដើម្បីជាជំនួយការក្នុងការរៀបចំសិក្ខាសាលា

- សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ
- គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ។

**ប្រការ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឯកឧត្តម អស់លោកដែលមានឈ្មោះក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះ រហូតដល់ដំណើរការនៃសិក្ខាសាលានេះត្រូវបានបញ្ចប់ដោយជោគជ័យ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែមេសា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
អគ្គលេខាធិការរាជរដ្ឋាភិបាល
ដូចប្រការ ៤
រាជកិច្ច
ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ...១៤ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការជាតិកែទម្រង់ការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៦ ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ :** បង្កើតគណៈកម្មការជាតិកែទម្រង់ការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ រួមមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម **ស ខេង** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២- ឯកឧត្តម **ទៀ បាញ់** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ | ជាអនុប្រធាន |
| ៣- ឯកឧត្តម **ឯម សំអាន** | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | ជាសមាជិកទទួលបន្ទុកអចិន្ត្រៃយ៍ |
| ៤- ឯកឧត្តម **អង្គ វង្សវឌ្ឍានា** | រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ | ជាសមាជិក |
| ៥- ឯកឧត្តម **ចាយ សាំងយ៉ុន** | រដ្ឋលេខាធិការ ក្រសួងការពារជាតិ | ជាសមាជិក |
| ៦- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៧- ឯកឧត្តម **ប៊ុន អ៊ុយ** | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |

៨- ឯកឧត្តម **កែ គឹមយ៉ាន** អគ្គមេបញ្ជាការកងយោធពលខេមរៈភូមិន្ទ ជាសមាជិក

៩- ឯកឧត្តម **ហុក ឡុងឌី** អគ្គស្នងការនគរបាលជាតិ ជាសមាជិក

**ប្រការ២ :** គណៈកម្មការជាតិកែទម្រង់ការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ មានតួនាទី ភារកិច្ចដឹកនាំកិច្ចការមួយចំនួនដូចខាងក្រោម :

- តាក់តែងលិខិតបទដ្ឋាន សម្រាប់ការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ និងពង្រឹងការអនុវត្តច្បាប់នេះឱ្យមានប្រសិទ្ធភាព ។
- កសាងផែនការសកម្មភាព ស្តីពីការប្រយុទ្ធប្រឆាំង ការរីករាលដាលនៃអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ស្របតាមច្បាប់ជាតិ និងលិខិតុបករណ៍អន្តរជាតិ ។
- បន្តកែទម្រង់ការគ្រប់គ្រងប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ក្នុងកងកម្លាំងឯកសណ្ឋាន មន្ត្រី និងស្ថាប័នសាធារណៈ ។
- ជំរុញការប្រមូលដកហូតអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ដែលនៅសេសសល់រាយប៉ាយក្រៅការគ្រប់គ្រង ។
- ពិនិត្យសម្រេចពីបរិមាណ ប្រភេទ គុណភាព នៃអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវ ដែលត្រូវបំផ្លាញចោល ។
- ទំនាក់ទំនងសហប្រតិបត្តិការជាមួយបណ្តាអង្គការ សហគមន៍ជាតិ អន្តរជាតិ និងប្រទេសនានា សំដៅស្វែងរកការគាំទ្រផ្នែកបច្ចេកទេស ថវិកា និងសម្ភារៈ ។

**ប្រការ៣ :** គណៈកម្មការជាតិកែទម្រង់ការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ មានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយសម្រាប់ជំនួយការ និងប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ដើម្បីចាត់ចែងកិច្ចការ និងបង្កើតថ្នាក់គណនេយ្យដោយឡែកសម្រាប់គ្រប់គ្រងប្រើប្រាស់ថវិកា ។

**ប្រការ៤ :** សេចក្តីសម្រេចលេខ ៤១ សសរ ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈកម្មការជាតិកែទម្រង់ការគ្រប់គ្រងអាវុធជាតិផ្ទុះនៅកម្ពុជា និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្ត ក្រុងដែលពាក់ព័ន្ធ និងសាមុីខ្លួនដូចមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៣ សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការកែសំរួលគណៈកម្មាធិការសម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំង ចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចលេខ ១៣ សសរ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការ សម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ
- យោងតាមតំរូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១:** ត្រូវបានកែសំរួលគណៈកម្មាធិការសម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សា សន្តិភាពរបស់អង្គការសហប្រជាជាតិ ទៅជា គណៈកម្មាធិការជាតិ សម្របសម្រួលកិច្ចការបញ្ជូន កងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ។

**ប្រការ ២:** គណៈកម្មាធិការជាតិ មានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១- ឯកឧត្តម **ប្រាក់ សុខុន** | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម **ម៉ូច សំផន** | រដ្ឋលេខាធិការ ក្រសួងការពារជាតិ | អនុប្រធាន |
| ៣- ឯកឧត្តម **អ៊ូច បូរិទ្ធ** | រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការ អន្តរជាតិ | អនុប្រធាន |

៤- ឯកឧត្តម ឡុង វិស៊ុន រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន

៥- ឯកឧត្តម ឈឹម សុខន្តិ ទីប្រឹក្សា និងជានាយកខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ទៀ បាញ់ សមាជិកអចិន្ត្រៃយ៍

៦- ឯកឧត្តម សុខ ផេង អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល សមាជិក

៧- ឯកឧត្តម ជា តារា នាយរងសេនាធិការចំរុះនៃកងយោធពលខេមរភូមិន្ទ សមាជិក

៨- ឯកឧត្តម សំ ចណ្ណថន អគ្គលេខាធិការ ក្រសួងការពារជាតិ សមាជិក

៩- ឯកឧត្តម ស៊ុំ សំណាង អគ្គនាយក អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ ក្រសួងការពារជាតិ សមាជិក

១០- ឯកឧត្តម ចៅ តិរុណ អគ្គនាយក អគ្គនាយកដ្ឋានសំភារៈ-បច្ចេកទេស ក្រសួងការពារជាតិ សមាជិក

១១- ឯកឧត្តម មាស សាវ៉ន អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា ក្រសួងការពារជាតិ សមាជិក

១២- ឯកឧត្តម ខ្វាន់ ស៊ាម មេបញ្ជាការ កងវិស្វកម្ម អគ្គបញ្ជាការ សមាជិក

១៣- ឯកឧត្តម មាស សំរុល នាយកនាយកដ្ឋានបុគ្គលិក ក្រសួងការពារជាតិ សមាជិក

១៤- ឯកឧត្តម ស៊ែម សុចណ្ណនី អគ្គលេខាធិការរង អាជ្ញាធរមីន សមាជិក

១៥- តំណាង ក្រសួងមហាផ្ទៃ សមាជិក

១៦- តំណាង ក្រសួងសាធារណៈការ និងដឹកជញ្ជូន សមាជិក

ប្រការ ៣: គណៈកម្មាធិការជាតិ មានបេសកកម្ម តួនាទី និងភារកិច្ច ដូចខាងក្រោម :

- សំរបសំរួលកិច្ចការទាំងឡាយ ដែលពាក់ព័ន្ធនឹងការត្រៀមរៀបចំកំលាំងទៅចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ជាមួយក្រសួង ស្ថាប័នផ្សេងៗ ។
- ទំនាក់ទំនងជាមួយ អ.ស.ប ក្នុងការរៀបចំឯកសារ លិខិតបទដ្ឋាននានា សំរាប់បញ្ជូនចូលរួមបំពេញបេសកកម្មរបស់ អ.ស.ប រួមមាន កំលាំងបោសសំអាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ នាយទាហានសង្កេតការណ៍ បុគ្គលិកធ្វើការក្នុងក្របខ័ណ្ឌ អ.ស.ប និងការងារ ផ្សេងៗទៀត តាមតំរូវការរបស់ អ.ស.ប និងតាមលទ្ធភាពរបស់កម្ពុជា ។
- លើកយោបល់ និងសំណើផ្ទាល់ជូនរាជរដ្ឋាភិបាលជ្រាប ពិនិត្យ និងសំរេចលើរាល់កិច្ចការពាក់ព័ន្ធនឹងការត្រៀមរៀបចំកំលាំងទៅចូលរួមបេសកកម្មរក្សាសន្តិភាព អ.ស.ប ។
- លើកគំរោងថវិកាសំរាប់បំពាក់ឧបករណ៍នានា និងបរិការងារហ្វឹកហ្វឺន ជូនកងកំលាំងគ្រប់ប្រភេទ ដែលនឹងចូលរួមបេសកកម្មរបស់ អ.ស.ប ។

- ទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន សហគមន៍អ្នកផ្តល់ជំនួយ អង្គការជាតិ និងអន្តរជាតិ ដើម្បីកៀងគររកជំនួយគាំទ្រ ។
- បូកសរុបរបាយការណ៍សកម្មភាពការងារ និងលទ្ធផល ជូនរាជរដ្ឋាភិបាល ។
- អនុវត្តកិច្ចការមួយចំនួនទៀត តាមការប្រគល់ភារកិច្ចពីរាជរដ្ឋាភិបាល ។

**ប្រការ ៤:** គណៈកម្មាធិការជាតិ មានកញ្ចប់ថវិកាសំរាប់ដំណើរការក្នុងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៥:** គណៈកម្មាធិការជាតិ សហការជាមួយក្រសួងការពារជាតិ និងអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទដើម្បីបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលផ្នែកប្រតិបត្តិការរក្សាសន្តិភាព អ.ស.ប ។

**ប្រការ ៦:** គណៈកម្មាធិការជាតិ មានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៧:** គណៈកម្មាធិការជាតិ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៨:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងសាមីខ្លួនក្នុងប្រការ ២ ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៨*
- *រាជកិច្ច*
- *ឯកសារ - កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៦៩២ ពណ.នគក

ភ្នំពេញថ្ងៃទី០៧ ខែ មិនា ឆ្នាំ ២០០៦

បានចុះបញ្ជី
ថ្ងៃទី ៤ ខែ ៤ ឆ្នាំ ២០០៦

# សេចក្តីជូនដំណឹង រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ភី អេច ភី**

**P H P Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co.2815/06E** ចុះថ្ងៃទី ០២ ខែ មិនា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក PHILIPPE STOTVOYNER ប្រធានក្រុមប្រឹក្សាភិបាល

លោក PIERRE, HENRI WIRTH អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៦២៨ ផ្លូវលំ ភូមិមិត្តភាព ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្តាល

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ ពិសេសនាំចូល ទិញ លក់ សំភារៈសំណង់ គ្រឿងចក្រ សំលៀកបំពាក់ គ្រឿងឧបភោគបរិភោគ គ្រឿងអគ្គីសនីគ្រប់ប្រភេទ គ្រឿងសង្ហារឹម រថយន្ត ទោចក្រយានយន្ត និងគ្រឿងបន្លាស់រថយន្តគ្រប់ប្រភេទ ខ្សាច់ គ្រួស គ្រួសក្រហម ថ្នាំ គីមី និងជីបំរើអោយវិស័យកសិ-ឧស្សាហកម្ម

-ការជួលដាក់ឃ្លាំងទូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម អចលនទ្រព្យ

-ស្ថានីយ៍ប្រេងឥន្ធនៈ

-យានដ្ឋាន

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន ម៉ាស្សា រមណីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ នេសាទទឹកសាប ទឹកប្រៃ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រកិនថ្ម រោងចក្ររ៉ែគ្រប់ប្រភេទ

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ជ.រដ្ឋមន្ត្រីស្តីទី

គឹម ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាខេត្តកណ្តាល
- មន្ទីរពាណិជ្ជកម្មខេត្តកណ្តាល "មុខការ"
- ឯកសារ -កាលប្បវត្តិ

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ៦៩៤ ពណ.នគក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ភ្នំពេញថ្ងៃទី០៧ ខែមិនា ឆ្នាំ ២០០៦

ចុះបញ្ជី
ថ្ងៃទី ៤ ខែ ៤ ឆ្នាំ2006

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អេជី ស៊ើវីស ខនសាល់ធីង**

**AG Services Consulting Co.,Ltd**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 2818/06E ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក David, Sébastien, Eric TREAL អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៣៣១ E2 វិថីព្រះស៊ីសុវត្ថិ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -សេវាយកកំរៃជើងសារទូទៅ-សេវាយកកំរៃជើងសារលើផ្នែកធានារ៉ាប់រងនិងហិរញ្ញវត្ថុ

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ

នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងទុវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្តវីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងផ្ទេរប្រាក់ទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប្រាជ្ញ ចន្ទ** (stamp and signature)

**គឹម_ស៊ីថន**

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
